**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៥ អនក្រ.បក

# អនុក្រឹត្យ

# ស្ដីពី

# ការរំសាយឡូត៍នេសាទក្នុងខេត្តកណ្ដាល កំពង់ចាម ព្រៃវែង និងតាកែវ និងរៀបចំជាតំបន់អភិរក្សជលផល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីជលផល
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្ដីពីការគ្រប់គ្រងសហគមន៍នេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្ដីពីការកែសម្រួលអត្ត

នាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្មនិងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**មាត្រា១.-**

លើកលែងតែតន្លងដាយត្រី ដាយបង្កង និងដាយត្រីលិញ ឡូត៍នេសាទទាំងអស់ក្នុងខេត្តកណ្តាល កំពង់ចាម តាកែវ និងព្រៃវែងត្រូវបានរំសាយជាកន្លែងនេសាទបំរុង ចាប់ពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ តទៅ ដើម្បីប្រគល់ជូនប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារនិងមួយផ្នែករៀបចំធ្វើជាកន្លែងអភិរក្សជលផល។

**មាត្រា២.-**

រដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចុះរៀបចំបោះបង្គោលព្រំប្រទល់កន្លែងអភិរក្សជលផលនិងកន្លែងនេសាទគ្រួសារឱ្យបានច្បាស់លាស់ ដោយសហការជាមួយក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ។

**មាត្រា៣.-**

កន្លែងនេសាទដែលបានប្រគល់ជូនប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ ហាមដាច់ខាតមិនឱ្យជនណាមួយហ៊ុំហ៊ុំង ហែងយកទៅលក់ឬជួលឱ្យឯកជនធ្វើអាជីវកម្មផ្តាច់មុខឡើយ ។

ឧបករណ៍នេសាទជាលក្ខណៈគ្រួសារមិនចាំបាច់កំណត់ចំនួន និងមានវិសាលភាពអនុវត្តទូទាំងប្រទេស ។

**មាត្រា៤.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំប្រគល់កន្លែងនេសាទបំរុងជូនសហគមន៍នេសាទ ដើម្បីគ្រប់គ្រងនិងប្រើប្រាស់ប្រកបដោយការទទួលខុសត្រូវខ្ពស់ ។

**មាត្រា៥.-**

ចំពោះសហគមន៍នេសាទដែលមានកន្លែងនេសាទនៅជាប់ព្រំប្រទល់ប្រទេសវៀតណាម ត្រូវបានអនុញ្ញាតឱ្យបោះរបាំងផ្ទស់ចាប់ត្រី ប៉ុន្តែហាមដាច់ខាតមិនឱ្យជនណាមួយហ៊ុំងហែងយកទៅលក់ឬជួលឱ្យឯកជនធ្វើអាជីវកម្មផ្តាច់មុខឡើយ។ ទីតាំង និងទំហំនៃផ្ទស់ត្រូវកំណត់ក្នុងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ។

**មាត្រា៦.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្តល់ថវិកាឱ្យបានគ្រប់គ្រាន់សម្រាប់ការរៀបចំបោះបង្គោលព្រំប្រទល់ កន្លែងអភិរក្សធនធានជលផលទាំងអស់ ដើម្បីការពារឱ្យបានគត់មត់ល្អ។

**មាត្រា៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានអាជ្ញាធរទន្លេសាប រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកណ្តាល កំពង់ចាម ព្រៃវែង និងតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មីនា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល:</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- ឯកសារ កាលប្បវត្តិ